សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

# កិច្ចការស្រាវជ្រាវ

# មតកសាសន៍

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ

**-កែ ហុកស្រ៊ុន** **-នុត វណ្ណៈ**

**-សួរ ចំណាប់** **-សេង គន្ធា**

សាស្ត្រាចារ្យណែនាំ

លោក **ជ័យ រិទ្ធី**

ថ្នាក់ **បរិញ្ញាបត្រជាន់ខ្ពស់ នីតិសាស្ត្រ**

ជំនាញ **នីតិឯកជន** ជំនាន់ទី១០

ឆ្នាំចូលសិក្សា ២០១៣

ឆ្នាំសរសេរកិច្ចការស្រាវជ្រាវ ២០១៤

**រក្សាសិទ្ធិដោយ** Khmer Famous

# មាតិកា

**សេចក្ដីផ្ដើម** ........ 3

និយមន័យ ........ 4

ករណីទូទៅនៃការធ្វើមតកសាសន៍ ........ 4

ក.សមត្ថភាពរបស់មតកជន ........ 4

ខ.ទម្រង់នៃមតកសាសន៍ ........ 5

ខ.១.មតកសាសន៍ដោយលិខិតយថាភូត ........ 5

ខ.២.មតកសាសន៍ដោយលិខិតឯកជន ........ 6

ខ.៣.មតកសាសន៍ជាលិខិតសម្ងាត់ ........ 7

**២. ករណីពិសេសនៃការធ្វើមតកសាសន៍** ........ 8

ក.មតកសាសន៍នៃជននៅក្រោមអាណាព្យាបាលទូទៅ ........ 8

ខ.មតកសាសន៍នៃជនដែលកំពុងជួបប្រទះគ្រោះថ្នាក់ដល់អាយុជីវិត ........ 9

គ.មតកសាសន៍នៃជនដែលជាប់ឃុំឃាំងជាអាទិ៍ ........ 9

ឃ. មតកសាសន៍នៃបុគ្គលដែលមិនអាចនិយាយបានជាអាទិ៍ ........ 10

**ឯកសារយោង:** ........ 11

# សេចក្តីផ្តើម

នៅក្នុងជីវភាពរស់នៅរបស់មនុស្សជាតិរមែងតែង កើតចាស់ឈឺស្លាប់ ជារឿងមិនអាចប្រកែក បានពីជំនាន់មួយទៅជំនាន់មួយទៀត។ ពេលវេលាចេះតែបន្តដំណើរទៅមុខឥតឈប់ឈរ ហើយវ័យរបស់មនុស្សក៏ចម្រើនឡើងទៅតាមវគ្គនៃវ័យដែរគឺ ចាប់ផ្តើមពីចាប់កំណើតក្នុងផ្ទៃម្តាយ ប្រសូត្រមកជាមនុស្សមានមានសិទ្ធិ និងករណីកិច្ចគ្រប់គ្រាន់ហើយ ជាពិសេសពីមួយជំនាន់ទៅមួយជំនាន់សម្រាប់មនុស្សគ្រប់ៗគ្នាតែងសង្វាតរកទ្រព្យសម្រាប់ ចិញ្ចឹមជីវិតរៀងៗខ្លួនហើយ តាមទ្រឹស្តីអ្នកប្រាជ្ញ ក៏ដូចជាភាពជាក់ស្តែង មនុស្សជាតិតែងតែបន្សល់ទុកនូវបេតិកភណ្ឌ ដែលជាទ្រព្យសម្បត្តិរបស់ខ្លួនមុន និងក្រោយពេលមរណភាពទៅ។ ទ្រព្យដែលបន្សល់ទុកអាចជាទ្រព្យសកម្ម និងទ្រព្យអកម្ម មិនអាចថាបុគ្គលម្នាក់មុនពេល ឬ ក្រោយពេលមរណភាព ទៅមិនបន្សល់ទុកនូវបេតិកភណ្ឌនោះឡើយ។ ទ្រព្យសម្បត្តិដែលមតកជនបន្សល់ទុកនោះក៏មិនមែនថា ទ្រព្យនៃបុគ្គលមួយត្រូវតែធ្លាក់ទៅលើរដ្ឋនៃបុគ្គលនោះជាតែម្តងនោះដែរ ពោលគឺ មតកជនតែងបន្សល់នៅសន្តតិជន ឬញាតិសាច់សារលោហិតជាធម្មតាវិញ។ ដូចឆន្ទៈរបស់មតកជនលើទ្រព្យសម្បត្តិដែលមតិកជនខិតខំស្វែករកបបាននោះ គឺមតកជនមានគោលបំណងចង់បន្សល់ទុកអោយទាយាទរបស់ខ្លួនដែលជាសន្តតិជន។ មតកជនមានសិទ្ធិយ៉ាងពេញលេញទៅលើទ្រព្យសម្បត្តិដែលខ្លួនមាន គឺមតកជនមានសិទ្ធិគ្រប់គ្រាន់ក្នុងការបម្រុងទុកសម្រាប់ទាយាទរបស់ខ្លួនអោយទទួលបានតាមអ្វីដែលខ្លួនចង់បន្សល់ទុកអោយ។ មតកជនមានសិទ្ធិសម្រេចតាមឆន្ទៈគ្រប់យ៉ាងរបស់ខ្លួនតាំងតែពីពេលដែលខ្លួននៅពេលជីវិតនៅឡើយម្លេះ (គឺនៅពេលដែលខ្លួននៅជាប្រធាននៃសិទ្ធិនៅឡើយ) ហើយមានសិទ្ធិពេញលេញក្នុងការរក្សាសិទ្ធិផ្លាស់ប្តូរ កែប្រែ ឬលុបចោលនៅឆន្ទៈរបស់ខ្លួនបាន។ មតកជនអាចបង្ហាញឆន្ទៈនេះបានតាមរយៈការធ្វើមតកសាសន៍។ ការធ្វើមតកសាសន៍មានចែងក្នុងក្រមរដ្ឋប្បវេណីថ្មីឆ្នាំ ២០០៧ ត្រង់ មាត្រា ១១៦៨-១២២៧ ។ ដើម្បីអោយយល់ច្បាស់អំពីមតកសាសន៍ និងមានបង្ហាញនូវ និយមន័យ( ១) ករណីទូទៅនៃការធ្វើមតកសាសន៍ (២) ករណីពិសេសនៃការធ្វើមតកសាសន៍(ផ្នែកទី៣)។

## និយមន័យ

មតិក គឺជាទ្រព្យសម្បត្តិ ឬជាកេរទាំងឡាយណាដែលបុគ្គលម្នាក់(មតកជន) បានបន្សល់ទុកក្រោយពេលស្លាប់។

មតកជន គឺជាជនដែលស្លាប់ទៅហើយ។

សន្តតិជន គឺជាជនដែលទទួលបន្តនូវសិទ្ធិ និងករណីកិច្ចរបស់មតកជនតាមរយៈសន្តតិកម្ម។

សន្តតិកម្ម គឺជាការផ្ទេរនូវសិទ្ធិ និង ករណីកិច្ចរបស់មតកជនទៅឱ្យសន្តតិជនម្នាក់ ឬ ច្រើននាក់តាមឆន្ទៈ ឬ តាមច្បាប់។

មតកសាសន៍ គឺជាលិខិតបណ្តាំដែលបុគ្គលម្នាក់ធ្វើឡើងតាមទម្រង់ដែលកំណត់ដោយច្បាប់ដើម្បីសម្តែងឆន្ទៈចុងក្រោយអំពីការចាត់ចែងទ្រព្យសម្បត្តិ របស់ខ្លួនជាអាទ័បន្ទាប់ពីមរណ ភាព។

## ករណីទូទៅនៃការធ្វើមតកសាសន៍

មតកសាសន៍ គឺជាការបង្ហាញឆន្ទៈផ្ទាល់របស់មតកជនក្នុងការផ្ទេរនូវសិទ្ធិ និងកាតព្វកិច្ចរបស់ខ្លួនទៅសន្តតិជនរបស់ខ្លួនក្នុងរូបភាពជាលិខិតមតិត ហើយជាវិធីមួយដែលអាចធ្វើសន្តតិកម្មទៅអោយសន្តតិជនរបស់មតកជនបាន។ ជាទូទៅដើម្បីអាចបង្កើតមតកសាសន៍មតកជន ចាំបាច់ត្រូវមានសមត្ថភាពក្នុងការបង្កើតមតកសាសន៍(ក) ទៅតាមទម្រង់ដែលច្បាប់កំណត់(ខ)ហើយសរសេរនូវចំណុចមួយចំនួនដែលចាំបាច់ ឬ ដែលខ្លួនមានឆន្ទៈក្នុងការសរសេរ(គ)ឬក៏អាចធ្វើការកំណត់នូវអច្ច័យទាន(ឃ) នូវក្នុងមតកសាសន៍នោះបាន។

### ក.សមត្ថភាពរបស់មតកជន

អ្នកដែលអាចធ្វើមតកសាសន៍បានគឺជា បុគ្គលដែលមានសមត្ថភាពផ្លូវច្បាប់ នៅពេលធ្វើមតកសាសន៍។បុគ្គលដែលច្បាប់អនុញ្ញាតអោយធ្វើមតកសាសន៍គឺ ជាបុគ្គលដែលជានីតិជនតាមផ្លូវច្បាប់ ដោយមិនគិតថាបុគ្គលនោះមានសមត្ថភាពពេញលេញ ឬ មិនពេញលេញនោះទេ ព្រោះនីតិជនដែលស្ថិតនៅក្រោមអាណាព្យាបាលទូទៅ ឬ ស្ថិតនៅក្រោមហិតូបត្ថកៈ ក៏អាចធ្វើមតកសាសន៍បានដែរ តែក្នុងករណីដែលជននោះមានស្មារតីឡើងវិញមួយរយៈ ហើយក៏ត្រូវបានអ្នកជំនាញ

បញ្ជាក់ពីការមានស្មារតីនោះដែរ។ ដូច្នេះការលប់ចោលមតកសាសន៍ដោយអះអាងនូវអសមត្ថភាពពីអាណាព្យាបាលទូទៅ ឬ ហិតូបម្ភកៈ គឺមិនអាចធ្វើទៅបានទេ។ ចំពោះអនីតិជន ក៏អាចធ្វើមតកសាសន៍បានដែរប្រសិនបើជននោះ មានសមត្ថភាពដោយរួចផុតពីអាណាព្យាបាលសម្រាប់អនីតិជន ដោយមូលហេតុទទួលបាននូវអត្តាធីនភាពតាមផ្លូវច្បាប់។[1]

ការមានសមត្ថភាពតែមួយ មិនទាន់គ្រប់គ្រាន់ទេ បុគ្គលនោះត្រូវតែមានសមត្ថភាពនៅពេលធ្វើមតកសាសន៍ទៀត[2] ទើបអាចធ្វើមតកសាសន៍បាន។ សមត្ថភាពនេះគឺសំដៅទៅលើ សមត្ថភាពខាងឆន្ទៈ នៅពេលធ្វើមតកសាសន៍។ ប្រសិនបើជននោះធម្មតាជាជនមានសមត្ថភាព ប៉ុន្តែនៅពេលធ្វើមតកសាសន៍ក្លាយជាអសមត្ថជនវិញនោះ ដូចជាស្រវឹង ឬ ស្រាប់តែកើតជម្ងឺវង្វេង ជាបញ្ហាដែលធ្វើអោយមតកសាសន៍នោះមោឃភាពទាំងស្រុង។

ក្រៅពីសមត្ថភាពរបស់មតកជន មតកសាសន៍ក៏ត្រូវតែបង្កើតឡើងក្រោមទម្រង់ណាមួយដែលក្រមរដ្ឋប្បវេណីថ្មី បានបញ្ញត្តទើបធ្វើអោយលិខិតមួយនោះមានសុពលភាព។[3]

## ខ.ទម្រង់នៃមតកសាសន៍

ដោយយោងតាមក្រមរដ្ឋប្បវេណីថ្មី ២០០៧ មតកជនអាចបង្ហាញឆន្ទៈក្នុងការកំណត់មតកសាសន៍ទៅសន្តតិជនរបស់ខ្លួនបានតាមទម្រង់ណាមួយក្នុងចំណោមទម្រង់ទាំងបីគឺៈ ទម្រង់ជាលិខិតយថាភូត (ខ.១) ទម្រង់ជាលិខិតឯកជន(ខ.២) និងជាទម្រង់លិខិតសម្ងាត់(ខ.៣) ដើម្បីអោយមតកសាសន៍របស់ខ្លួនមានសុពលភាព។[4]

### ខ.១.មតកសាសន៍ដោយលិខិតយថាភូត[5]

មតកសាសន៍តាមទម្រង់លិខិតយថាភូត គឺជាមតកសាសន៍ដែលបានបង្កើតឡើងដោយម្ចាស់បណ្តាំ នៅចំពោះមុខសាការី តាមទម្រង់ដែលបានកំណត់ដូចជាៈ

[1] មាត្រា ១១៦៨ នៃក្រមរដ្ឋប្បវេណីថ្មីឆ្នាំ ២០០៧។
[2] មាត្រា ១១៦៩ នៃក្រមរដ្ឋប្បវេណីថ្មីឆ្នាំ ២០០៧។
[3] កថាខ័ណ្ឌទី១ មាត្រា ១១៧០ នៃក្រមរដ្ឋប្បវេណីថ្មីឆ្នាំ ២០០៧។
[4] មាត្រា ១១៧១ នៃក្រមរដ្ឋប្បវេណីថ្មីឆ្នាំ ២០០៧។
[5] មាត្រា ១១៧៣ នៃក្រមរដ្ឋប្បវេណីថ្មីឆ្នាំ ២០០៧។

(១) ត្រូវមានវត្តមានរបស់សាក្សីយ៉ាងតិចពីរនាក់

(២) ម្ចាស់បណ្តាំត្រូវប្រាប់ផ្ទាល់នូវខ្លឹមសារនៃមតកសាសន៍ចំពោះសាការី ហើយ

(៣) សាការីត្រូវសរសេរនូវអត្ថន័យ នៃមតកសាសន៍របស់ម្ចាស់មតកសាសន៍នោះជា លាយល័ក្ខអក្សរ ហើយត្រូវសូត្រអោយម្ចាស់បណ្តាំនឹងសាក្សីនោះស្តាប់។

(៤) បន្ទាប់ពីម្ចាស់បណ្តាំ និងសាក្សី បានទទួលស្គាល់ថាកំណត់ជាលាយល័ក្ខអក្សរនោះត្រឹមត្រូវហើយជននីមួយៗនោះត្រូវចុះហត្ថលេខារៀងៗខ្លួន ឬ សាការីត្រូវសរសេរនូវហេតុដែលមានបុគ្គលណាម្នាក់មិនចេះចុះហត្ថលេខា ដើម្បីបញ្ជាក់ពីឈ្មោះ អាយុ និងលំនៅស្ថាន ហើយ

(៥) ជាចុងក្រោយសាការីត្រូវសរសេរថ្ងៃ ខែ ឆ្នាំ ហើយត្រូវចុះហត្ថលេខា។

មតកជនក៏អាចមិនធ្វើមតកសាសន៍ដោយលិខិតយថាភូតបាន ឬ មតកជនអាចធ្វើមតកសាសន៍របស់ខ្លួនជាលក្ខណៈឯកជន។

### ខ.២.មតកសាសន៍ដោយលិខិតឯកជន[6]

ចំពោះមតកសាសន៍តាមទម្រង់លិខិតឯកជន គឺជាមតកសាសន៍ដែលត្រូវបានធ្វើឡើងដោយម្ចាស់បណ្តាំ ដោយសរសេរនូវពាក្យទាំងអស់ និង ចុះថ្ងៃ ខែ ឆ្នាំ ដោយខ្លួនឯងផ្ទាល់ដៃ ត្រូវចុះហត្ថលេខាលើលិខិត ដើម្បីអោយលិខិតមតកសាសន៍នោះមានសុពលភាពប៉ុន្តែប្រសិនបើអោយអ្នកដទៃសរសេរជំនួយ នោះមតកសាសន៍នឹងចាត់ទុកជាមោឃ ចំពោះការបន្ថែម ការលុប ឬ ការកែប្រែផ្សេងទៀតនៅក្នុងមតកសាសន៍ ចាំបាច់ម្ចាស់បណ្តាំត្រូវបង្ហាញនូវកន្លែង ហើយសរសេរបន្ថែមនូវហេតុនៃការកែប្រែនោះ ជាពិសេសត្រូវចុះហត្ថលេខាបញ្ជាក់អំពីហេតុនោះ។

ម្យ៉ាងទៀតមតកជនអាចធ្វើមតកសាសន៍របស់ខ្លួនដោយមិនយក ទម្រង់ទាំងពីរខាងលើគឺ ទម្រង់ជាលិខិតយថាភូត និង លិខិតឯកជន មតកជនអាចធ្វើមតកសាសន៍របស់ខ្លួនតាមទម្រង់នៃលិខិតសម្ងាត់បាន។

[6] មាត្រា ១១៧៤ នៃក្រមរដ្ឋប្បវេណីថ្មីឆ្នាំ ២០០៧។

## ខ.៣.មតកសាសន៍ជាលិខិតសម្ងាត់[7]

រីឯមតកសាសន៍ដោយលិខិតសម្ងាត់វិញ គឺជាមតកសាសន៍ដែលបានបង្កើតឡើងដោយម្ចាស់បណ្ដាំធ្វើឡើងដោយខ្លួនឯង តាមល័ក្ខខ័ណ្ឌដូចខាងក្រោមៈ

(១) ម្ចាស់បណ្ដាំត្រូវចុះហត្ថលេខាលើលិខិតនោះ

(២) ហើយត្រូវដាក់លិខិតនោះក្នុងស្រោមបិទជិត ហើយត្រូវចុះហត្ថលេខា ឬសរសេរសញ្ញាសំគាល់ ឬមធ្យោបាយផ្សេងទៀតដែលអាចវិនិច្ឆ័យបានអំពីការបើក ឬ មិនបានបើកស្រោមលិខិតនោះនៅមាត់ស្រោមលិខិតនោះ

(៣) បន្ទាប់មកម្ចាស់បណ្ដាំត្រូវយកទៅដាក់នៅចំពោះមុខសារការី និងសាក្សី ២នាក់ ហើយធ្វើសេចក្ដីថ្លែងការណ៍ថា លិខិតនោះជាលិខិតមតកសាសន៍របស់ខ្លួន ប៉ុន្តែប្រសិនបើមានអ្នកដទៃសរសេរជំនួសត្រូវធ្វើសេចក្ដីថ្លែងការណ៍អំពីឈ្មោះ និងលំនៅឋានរបស់ជនដែលបានសរសេរនោះ

(៤) បន្ទាប់មកសារការីត្រូវចុះថ្ងៃ ខែ ឆ្នាំ ដែលម្ចាស់បណ្ដាំបានដាក់ ហើយសរសេរនូវសេចក្ដីថ្លែងការណ៍របស់ម្ចាស់បណ្ដាំនៅលើលិខិតដែលបិទជិតនោះ ហើយត្រូវចុះហត្ថលេខាលើលិខិតនោះជាមួយនិងសាក្សី និង ម្ចាស់បណ្ដាំ។

ក្រោយពេលដែលមតកជនបានធ្វើការជ្រើសរើសរួចនូវទម្រង់មតកសាសន៍ មតកជនត្រូវធ្វើការកំណត់នូវចំណុចមួយចំនួនក្នុងមតកសាសន៍ដូចជាចំណែកមត៌កនៃសហសន្តតិជន ការឲ្យ ដំបូន្មានទៅសហសន្តតិជន ឬ ចំណុចផ្សេងៗទៀតដែលខ្លួនយល់ថាគួរតែកំណត់ក្នុងនោះ។

លើសពីនេះទៅទៀតក្រៅពីការធ្វើ មតកសាសន៍ខាងលើមតកជនអាចធ្វើមតកសាសន៍បានទោះជាមតកជនបានជួបនឹងករណីពិសេសមួយចំនួនក៏ដោយ។

[7] មាត្រា ១១៧៤ នៃក្រមរដ្ឋប្បវេណីថ្មីឆ្នាំ ២០០៧។

# ២. ករណីពិសេសនៃការធ្វើមតកសាសន៍

ជាគោលការណ៍មតកសាសន៍ត្រូវមានសមត្ថភាពគ្រប់គ្រាន់ក្នុងការធ្វើមតកសាសន៍។ ប៉ុន្តែក្នុងករណីដែលមតកជនជួបនូវករណីពិសេសណាមួយដែលបានកំណត់ដោយ ក្រមរដ្ឋប្បវេណីថ្មី មតកជនក៏អាចធ្វើមតកសាសន៍បានដែរទោះជាខ្លួនពុំមានសមត្ថភាពគ្រប់គ្រាន់។ ករណីពិសេសមានដូចជាៈ ការធ្វើមតកសាសន៍នៃជននៅក្រោមអាណាព្យាបាលទូទៅ(ក)មតកសាសន៍នៃជនដែលកំពុងជួបប្រទះគ្រោះថ្នាក់ដល់អាយុជីវិត(ខ) មតកសាសន៍នៃជនដែលត្រូវជាប់ឃុំឃាំងជាអាទិ៍(គ) និង មតកសាសន៍នៃបុគ្គលដែលមិនអាចនិយាយបានជាអាទិ៍(ឃ)។

## ក.មតកសាសន៍នៃជននៅក្រោមអាណាព្យាបាលទូទៅ[8]

ចំពោះជនដែលស្ថិតនៅក្រោមអាណាព្យាបាលទូទៅ មិនមែនគ្រប់ពេលសុទ្ធតែមិនអាចធ្វើកិច្ចការដែលសំខាន់ៗបានទេ ជាពិសេសការធ្វើមតកសាសន៍។ ជនប្រភេទនេះក៏ត្រូវបានច្បាប់អនុញ្ញាតអោយធ្វើមតកសាសន៍បានដែរ តែត្រូវស្ថិតនៅក្នុងល័ក្ខខ័ណ្ឌនៃពេលដែលជននោះមានស្មារតីធូរស្បើយមួយរយៈឡើងវិញ នៅសមត្ថភាពយល់ដឹងនិងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់ ហើយត្រូវមានវត្តមានរបស់វេជ្ជបណ្ឌិតយ៉ាងតិច ២នាក់។ ហើយវេជ្ជបណ្ឌិតទាំងនោះត្រូវសរសេរបញ្ជាក់បន្ថែមលើលិខិតមតកសាសន៍នោះថា នៅពេលធ្វើគឺជននោះមានសមត្ថភាពគ្រប់គ្រាន់ខាងសមត្ថភាពយល់ដឹង និង វិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ហើយត្រូវចុះហត្ថលេខាដោយបញ្ជាក់ថាខ្លួនជាវេជ្ជបណ្ឌិតផង។

ប៉ុន្តែ ករណីលើកលែងចំពោះអនីតិជនដែលត្រូវបានប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅ គឺមិនអាចធ្វើលិខិតមតកសាសន៍បាននោះទេ ដោយត្រូវរងចាំរហូតដល់ពេលក្លាយជានីតិជនសិន។ រីឯការធ្វើលិខិតមតកសាសន៍ដោយលិខិតយថាភូតចាំបាច់ត្រូវមានសាក្សីបន្ថែម ២នាក់ទៀតលើវត្តមានរបស់គ្រូពេទ្យ ឯមតកសាសន៍តាមទម្រង់ផ្សេងទៀតមិនចាំបាច់ទេ។

ករណីមួយទៀតក្នុងការធ្វើមតកសាសន៍ គឺការធ្វើមតកសាសន៍ដោយជនដែលកំពុងជួបគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត។

[8] មាត្រា ១១៧៦ នៃក្រមរដ្ឋប្បវេណីថ្មីឆ្នាំ ២០០៧។

## ខ.មតកសាសន៍នៃជនដែលកំពុងជួបប្រទះគ្រោះថ្នាក់ដល់អាយុជីវិត[9]

រីឯជនដែលកំពុងជួបប្រទះគ្រោះថ្នាក់ដល់អាយុជីវិត ក៏អាចធ្វើមតកសាសន៍ក្រោមទម្រង់ណាមួយបានដែរដោយតម្រូវអោយមានសាក្សីយ៉ាងតិច ៣នាក់ ហើយត្រូវប្រកាសខ្លឹមសារនៃមតកសាសន៍នោះដោយផ្ទាល់មាត់ទៅជនម្នាក់ក្នុងចំណោមនោះ ហើយជនដែលបានស្តាប់នោះត្រូវតែសរសេរជាលាយល័ក្ខអក្សរ ហើយត្រូវអានអោយសាក្សី ២នាក់ទៀតស្តាប់ ឬឲ្យមើលបន្ទាប់មកសាក្សីទាំង ២ត្រូវចុះហត្ថលេខាបញ្ជាក់ថាត្រឹមត្រូវហើយ។ ម៉្យាងទៀតល័ក្ខខ័ណ្ឌតែប៉ុណ្ណឹងគឺមិនទាន់អាចធ្វើអោយមតកសាសន៍នោះមានសុពលភាព ដោយចាំបាច់ត្រូវមានការបញ្ជាក់ពីតុលាការទៀតក្នុងអំឡុងពេលមួយឆ្នាំគិតចាប់ពីថ្ងៃធ្វើមតកសាសន៍ហើយប្រសិនបើតុលាការ មិនមានជំនឿទុកចិត្តទៀតនោះមតកសាសន៍នោះនឹងគ្មានសុពលភាពប្រើប្រាស់ទេ។

ករណីជនដែលត្រូវជាប់ឃុំឃាំង ឬ នៅក្នុងនាវាជាអាទិ៍ច្បាប់ក៏អនុញ្ញាតអោយមានសិទ្ធិធ្វើមតកសាសន៍បានដែរ។

## គ.មតកសាសន៍នៃជនដែលជាប់ឃុំឃាំងជាអាទិ៍[10]

ជនដែលត្រូវជាប់ឃុំឃាំង ឬនៅក្នុងនាវា ឬយន្តហោះក៏អាចធ្វើមតកសាសន៍បានដែរដោយមានវត្តមានរបស់មន្ត្រីនៃមន្ទីរឃុំឃាំង ឬនគបាលម្នាក់ មេបញ្ជាការ ឬក៏បរិបាលនាវា ឬបុគ្គលិកនាវា យន្តហោះ និងសាក្សីយ៉ាងតិច ២នាក់។ ការធ្វើមតកសាសន៍ក្នុងស្ថានភាពបែបនេះគឺត្រូវយក ទម្រង់លិខិតយថាភូតមកអនុវត្តដោយយកមន្ត្រីសាធារណៈទាំងនោះជាសាការី។ ការយកតែទម្រង់លិខិតយថាភូតមកអនុវត្តព្រោះគំនិតក្នុងមាត្រានេះ គឺផ្តោតសំខាន់ទៅលើជនដែលមិនសង្ឃឹមថានឹងរស់ក្រោយពេលដែលខ្លួនបានចេញពីមន្ទីរឃុំឃាំង នាវា យន្តហោះ ក្នុងអំឡុងពេល ៦ខែគិតពីថ្ងៃដែលអាចធ្វើមតកសាសន៍បានដោយខ្លួនឯងក្រោយទម្រង់ទាំងបីខាងលើ មតកសាសន៍ដែលអាចធ្វើពេលជាប់ឃុំ ក្នុងនាវា យន្តហោះ នោះនឹងពុំមានអានុភាពឡើយ។

ក្រៅពីករណីខាងលើនេះមតកសាសន៍ក៏អាចធ្វើបានដែរដោយបុគ្គលដែលមិនអាចនិយាយ ឬមិនអាចស្តាប់បានជាអាទិ៍។

[9] មាត្រា ១១៧៧ នៃក្រមរដ្ឋប្បវេណីថ្មីឆ្នាំ ២០០៧។
[10] មាត្រា ១១៧៨ នៃក្រមរដ្ឋប្បវេណីថ្មីឆ្នាំ ២០០៧។

## ឃ. មតកសាសន៍នៃបុគ្គលដែលមិនអាចនិយាយបានជាអាទិ៍[11]

ករណីដែលម្ចាស់បណ្តាំជាបុគ្គលដែលបានបាត់បង់នៅកាយសម្បទាន ផ្នែកណាមួយនៃខ្លួនប្រាណជាពិសេសបុគ្គលដែលមិនអាចនិយាយ ឬស្តាប់បានក៏អាចធ្វើមតកសាសន៍បានតាមទម្រង់ណាមួយខាងលើដោយធ្វើសេចក្តីថ្លែងការណ៍ពីខ្លឹមសារនៃមតកសាសន៍ ឬសេចក្តីថ្លែងការណ៍លើលិខិតនោះជាមតកសាសន៍ ហើយត្រូវមានអ្នកបកប្រែ ក្នុងការបកប្រែនូវភាសាដែលបុគ្គលនោះខ្វះសម្បទាជាមតកជនប្រើប្រាស់ ប្រសិនបើអ្នកនោះចេះសរសេរអាចសរសេរដោយខ្លួនឯងផ្ទាល់នៅចំពោះមុខសាការី ឬសាក្សី។ ក្រោយពេលសរសេររួចសាការីត្រូវអាននូវខ្លឹមសារនៃមតកសាសន៍អោយមតកជន និងសាក្សីស្តាប់ ប៉ុន្តែក្នុងករណីដែលមតកជនជាបុគ្គលថ្លង់មិនអាចស្តាប់បានត្រូវជំនួយការអានឲ្យស្តាប់បានដោយប្រាប់អំពីអត្ថន័យដែលមតកជនបានសរសេរ ខ្លួនបានសរសេរតាមសេចក្តីថ្លែងការរបស់មតកជនតាមការបកប្រែរបស់អ្នកបកប្រែទៅមតកជន ឬសាក្សីនោះ។ ជាចុងក្រោយសាក្សីត្រូវសរសេរនូវហេតុរបស់ម្ចាស់បណ្តាំក្នុងលិខិតនោះផង៕

[11] មាត្រា ១១៧៩ នៃក្រមរដ្ឋប្បវេណីថ្មីឆ្នាំ ២០០៧។

# ឯកសារយោងៈ

១. ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧